# វៀតណាម ៖ ឈប់រំលោភខ្មែរក្រោម

## *រដ្ឋាភិបាលវៀតណាមបង្ក្រាបការតវ៉ាដោយសន្តិវិធីដើម្បីសិទ្ធិសាសនា, វប្បធម៌ និងដីធ្លី*

*(ញូយក, ថ្ងៃទី ២១ ខែមករា ឆ្នាំ២០០៩) – អង្គការឃ្លាំមើលសិទ្ធិមនុស្ស* (Human Rights Watch) *បាននិយាយនៅក្នុងរបាយការណ៍មួយដែល ចេញផ្សាយនៅថ្ងៃនេះថា រដ្ឋាភិបាលវៀតណាមត្រូវដោះលែងជាបន្ទាន់នូវព្រះសង្ឃនិងសកម្មជនសិទ្ធិដីធ្លីខ្មែរក្រោម ដែលស្ថិតក្នុងពន្ធនាគារ ឬស្ថិតក្រោមការឃុំឃាំងក្នុងផ្ទះក្នុងប្រទេសវៀតណាម ដោយសារការបញ្ចេញមតិដោយសន្តិវិធី ខាងជំនឿសាសនានិងនយោបាយរបស់ពួកគេ ។*

*របាយការណ៍ចំនួន ១២៥ ទំព័រស្តីពី ការរំលោភសិទ្ធិជាតិពន្ធខ្មែរក្នុងតំបន់ដីសណ្តរទន្លេមេគង្គនៃ ប្រទេសវៀតណាម ចងក្រងការរំលោភសិទ្ធិរបស់ខ្មែរក្រោមក្នុងប្រទេសវៀតណាមភាគខាងត្បូង និង អំពីការរំលោភនៅក្នុងប្រទេសកម្ពុជា ប្រឆាំងនឹងខ្មែរក្រោមដែលបានចូលមកកាន់ប្រទេសនេះ ។ រដ្ឋាភិបាលវៀតណាមបង្ក្រាបការសម្តែងមតិដោយសន្តិវិធី របស់អ្នកខ្វែងយោបល់ និងហាមឃាត់ខ្មែរក្រោមមិនឲ្យបោះពុម្ពផ្សាយសិទ្ធិមនុស្ស ។ ប្រទេសវៀតណាម ត្រួតត្រាយ៉ាងតឹងរ៉ឹងផងដែរលើព្រះសាសនានិយមទេវតា ដែលប្រតិបត្តិដោយខ្មែរក្រោម ។*

*លោក ប្រាដអាដាំ* (Brad Adams) *នាយកអង្គការសិទ្ធិមនុស្ស ប្រចាំទ្វីបអាស៊ីបានមានប្រសាសន៍ថា “ប្រតិកម្មរបស់រដ្ឋាភិបាលវៀតណាម ចំពោះការតវ៉ាដោយសន្តិវិធីរបស់ខ្មែរក្រោម បង្ហាញវិធីសាស្រ្តតឹងរ៉ឹង និងមិនផ្សាយឲ្យដឹងជាញឹកញយដែលប្រទេសនេះ*

ប្រើដើម្បី បំបិតមាត់អ្នកខ្មែរយោបល់ ។” “រដ្ឋាភិបាល វៀតណាម គួរតែព្យាយាមជជែកសន្ទនាជាមួយខ្មែរក្រោម ជាជាងចាប់បោះគ្រវែងពួកគេចូលទៅក្នុងពន្ធនាគារ ។”

របាយការណ៍នេះ ផ្តល់នូវដំណើររឿងពេញលេញអំពីការតវ៉ាមួយ ដែលដឹកនាំដោយព្រះសង្ឃខ្មែរក្រោមចំនួន ២០០ អង្គ ក្នុង ខេត្តឃ្លាំង (សុកត្រាំង) ប្រទេសវៀតណាម ក្នុងខែកុម្ភៈ ឆ្នាំ២០០៧ ។ អ្នកតវ៉ា បានអំពាវនាវសុំឲ្យមានសេរីភាពខាងសាសនាទូលំទូលាយជាងមុន និង ឲ្យមានការអប់រំភាសាខ្មែរច្រើនថែមទៀត ។ ទោះជាការតវ៉ាធ្វើឡើង ដោយសន្តិវិធី និងមានរយៈពេលត្រឹមតែពីរបីម៉ោងក៏ដោយ ក៏រដ្ឋាភិបាលវៀតណាមបានប្រតិកម្មយ៉ាង ខ្លាំង ។

ប៉ូលីសបានឡោមព័ទ្ធវត្តរបស់ព្រះសង្ឃដែលគេសង្ស័យថាដឹកនាំការតវ៉ា ។ អាជ្ញាធរមូលដ្ឋាននិងមន្ត្រីសង្ឃដែលតែងតាំងដោយរដ្ឋាភិបាល បានចាប់ផ្សឹកព្រះសង្ឃជាបន្តបន្ទាប់យ៉ាងហោចណាស់ ២០ អង្គដែរ និងបានបណ្តេញព្រះសង្ឃ ២៥ អង្គផ្សេងទៀត ចេញពីសាលាបាលីក្នុងខេត្តឃ្លាំង ។

អាជ្ញាធរបានបញ្ជូនព្រះសង្ឃត្រឡប់ទៅភូមិកំណើតវិញ និងដាក់ឃុំឲ្យនៅក្នុងផ្ទះ ឬស្ថិតក្រោមការឃុំឃាំងរបស់ប៉ូលីស ដោយគ្មានដីការចាប់ខ្លួន ឬដោយគ្មានការបញ្ជាក់ពីបទចោទប្រកាន់ប្រឆាំងនឹង ព្រះសង្ឃទាំងនោះឡើយ ។ នៅអំឡុងពេលសួរចម្លើយ ប៉ូលីសបានវាយព្រះសង្ឃមួយចំនួន ។

ក្នុងខែឧសភា ឆ្នាំ២០០៧ តុលាការ ខេត្តឃ្លាំង បានកាត់ទោសព្រះសង្ឃប្រាំអង្គលើបទចោទប្រកាន់អំពីការធ្វើខូចសណ្តាប់ធ្នាប់ចរាចរ និងវិនិច្ឆ័យទោសព្រះសង្ឃទាំងនោះដោយដាក់គុកពីពីរឆ្នាំដល់បួនឆ្នាំ ។ ព្រះសង្ឃមួយចំនួនត្រូវគេវាយដំអំឡុងពេលសួរ

ចម្លើយ ។ បន្ទាប់ពីការធ្វើបាតុកម្ម អាជ្ញាធរបានចាប់ផ្តើមឈ្លបមើលយ៉ាងតឹងរឹងលើ
សកម្មជនខ្មែរក្រោម, បានដាក់កំហិតនិងតាមដានចលនារបស់ពួកគេ, បានហាមការ
បោះពុម្ពផ្សាយរបស់ពួកគេ និងត្រួតពិនិត្យ ទូរស័ព្ទរបស់ពួកគេ ។

របាយការណ៍ពិចារណាផងដែរលើការរំលោភសិទ្ធិខ្មែរក្រោមដែលផ្លាស់ប្តូរមកកាន់ប្រទេស
កម្ពុជា ជាទីកន្លែងដែលពួកគេ ស្ថិតក្នុងចំណោមក្រុមក្រីក្របំផុតរបស់ប្រទេសនេះ ។
ពីព្រោះតែប្រជាពលរដ្ឋកម្ពុជាចាត់ពួកគេជាជាតិពន្ធវៀតណាម នាំឲ្យខ្មែរក្រោមជាច្រើន
ក្នុងប្រទេសកម្ពុជា ប្រឈមមុខនឹងការរើសអើងខាងសេដ្ឋកិច្ចនិងសង្គម និងឧបសគ្គ
មិនចាំបាច់ក្នុងការដាក់ពួកគេឲ្យមានឋានៈត្រឹមត្រូវតាមច្បាប់ ។

រដ្ឋាភិបាលកម្ពុជា បានថ្លែងម្តងហើយម្តងទៀតថា ខ្លួនពិចារណាខ្មែរក្រោមជាប្រជាពល
រដ្ឋខ្មែរ ។ ក៏ប៉ុន្តែ អាជ្ញាធរកម្ពុជា ជាញឹកញយប្រតិកម្មយ៉ាងខ្លាំង នៅខណៈពេលដែល
ខ្មែរក្រោមក្លាយជាគ្រឿងដ៏គ្រោះថ្នាក់របស់រដ្ឋាភិបាលវៀតណាម ។ ក្នុងឆ្នាំ ២០០៧
ប៉ូលីសកម្ពុជាប្រើកម្លាំងបំបែកដោយបង្ខំលើការ តវ៉ាបន្តបន្ទាប់ ក្នុងរាជធានីភ្នំពេញ
ដែលធ្វើឡើងដោយព្រះសង្ឃខ្មែរក្រោម ដែលបរិហារអំពីការរំលោភសិទ្ធិ ដែលពួក
គេបានទទួលរងនៅក្នុងប្រទេសវៀតណាម ។

ក្នុងខែកុម្ភៈ ឆ្នាំ២០០៧ ព្រះសង្ឃខ្មែរក្រោមមួយអង្គនាម អៀង សុខធឿន ត្រូវបានគេ
ធ្វើគត់ក្នុងកាលៈទេសៈគួរឲ្យសង្ស័យ បន្ទាប់ព្រះតេជគុណ បានចូលរួមក្នុងការតវ៉ាមួយក្នុង
រាធានីភ្នំពេញ ។ ក្នុងខែមិថុនា ឆ្នាំ២០០៧ អាជ្ញាធរកម្ពុជា បានចាប់ខ្លួន, ផ្សឹក និង
និរទេសសកម្មជនព្រះសង្ឃខ្មែរក្រោមមួយអង្គនាម ទឹម សាខន ដែលត្រូវបានគេវិនិច្ឆ័យ
ទោស ដាក់គុករយៈពេលមួយឆ្នាំក្នុងប្រទេសវៀតណាម ។

*អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានស្នើសុំឲ្យរដ្ឋាភិបាលកម្ពុជា ធ្វើការស៊ើបអង្កេតឲ្យបាន ហ្មត់ចត់លើការធ្វើគត់ព្រះសង្ឃ អៀង សុខធឿន។ អង្គការឃ្លាំមើលសិទ្ធិមនុស្សបានស្នើ សុំឲ្យរដ្ឋាភិបាលវៀតណាម ឲ្យអនុញ្ញាតឲ្យលោក ទឹម សាខន ដែលគេចាប់ដាក់ឃុំឲ្យនៅក្នុង ផ្ទះក្នុងប្រទេសវៀតណាមបន្ទាប់ពី លោកត្រូវបានគេដោះលែងពីពន្ធនាគារ ក្នុងខែឧសភា ឆ្នាំ២០០៨ ឲ្យវិញត្រឡប់មក ផ្ទះរបស់គាត់វិញក្នុងប្រទេសកម្ពុជា ប្រសិនបើគាត់ជ្រើស រើសការវិលត្រឡប់មកវិញ។*

*លោក ប្រាជអាដាំ បានមានប្រសាសន៍ថា “ការកាប់សម្លាប់, ការដាក់គុក និងការផ្សឹកព្រះ សង្ឃខ្មែរក្រោម បញ្ជូននូវសារដ៏រន្ធត់មួយទៅសកម្មជនខ្មែរក្រោម ទាំងនៅក្នុងប្រទេស កម្ពុជា និងប្រទេសវៀតណាម។” “ក្រុមជាតិពន្ធមួយដែលស្ថិតក្រោមការការពាររបស់ ប្រទេសពីរ តាមពិតទៅបែទៅជាអត់ទទួលបានការការពារពីប្រទេសទាំងពីរទៅវិញ។”*

## Selected Interviews from the Report

Please note that all names in quotation marks in the report are pseudonyms to protect interviewees from government reprisals.

*អាត្មាភាពបានត្រៀមដុតខ្លួនរួចហើយអាត្មាភាពមានដែកកេះ និងប្រេងសាំងមួយដប អាត្មាភាពបានរុំខ្លួននិង ត្រៃចីវររួចហើយ ប្រសិនបើគេមិនគោរពតាមសំណើររបស់អាត្មាភាពទេ អាត្មាភាពនឹងដុតខ្លួន។ អាត្មានិយាយថា «ប្រសិនបើអស់លោកមិនគោរពតាម អាត្មាភាពនឹងដុតខ្លួនអស់លោកនឹងទទួលខុសត្រូវ« ។ អាត្មាភាពបានគិតដូច្នោះ ពីព្រោះអា ត្មាភាពមិនបានធ្វើអ្វីខុសទេ។*

**- ព្រះសង្ឃខ្មែរក្រោមដែលត្រូវបានចាប់ខ្លួនបន្ទាប់ពីចូលរួមក្នុងការតវ៉ា ដោយ សន្តិវិធីនៅ ខេត្តឃ្លាំង កាលពី ខែ កុម្ភៈ ឆ្នាំ ២០០៧។**

*~~* *~~* *~~*

ដំបូងនគរបាលបានចោទសួរខ្ញុំរៀងរាល់ថ្ងៃក្រោយមកបីបួនលើកក្នុងមួយសប្តាហ៍។ ជួនកាលពួកគេសួរខ្ញុំតាំងតែពីពេលព្រឹករហូតដល់ម៉ោង ១០ យប់។ គេមិនអនុញ្ញាតឲ្យខ្ញុំទៅផ្ទះទេ។ ... ពួកគេយកបាតដៃរបស់គេមកទះផ្នែកខាងក្រោយក្បាលរបស់ខ្ញុំ និងវាយខ្ញុំជាមួយដុំរមូរក្រដាស។ ពួកគេសួរសំណួរមកខ្ញុំជាច្រើននិងព្យាយាមបំភ័យខ្ញុំដោយការបង្ហាញខ្នោះដៃ...ពួកគេបានសរសេរលិខិតឆ្លើយសារភាពទុកជាស្រេច។ ពួកគេបង្ខំឲ្យខ្ញុំឆ្លើយតាមអ្វីដែលពួកគេបានសរសេរ។បើមិនអញ្ចឹងទេ ពួកគេមិនអនុញ្ញាតឲ្យខ្ញុំហូបអាហារ ឬត្រឡប់ទៅផ្ទះទេ។ ខ្ញុំមិនប្រឆាំងរដ្ឋាភិបាលវៀតណាម ទេ។ ខ្ញុំគោរពតាមច្បាប់វៀតណាម។ ក៏ប៉ុន្តែពួកគេនិយាយថា ខ្ញុំមិនស្មោះត្រង់នឹង ជាតិ។

**-ព្រះសង្ឃខ្មែរក្រោមដែលត្រូវបានគេចាប់ផ្សឹក និងចាប់ដាក់ឃុំក្នុងផ្ទះបន្ទាប់ពីចូលរួមតវ៉ាដោយសន្តិវិធី នៅខេត្តឃ្លាំង ក្នុងឆ្នាំ២០០៧។**

*~~* *~~* *~~*

ព្រះសង្ឃទាំង ២ អង្គនេះស្ថិតនៅក្រោមការគាបសង្កត់ធ្ងន់ធ្ងរបំផុតដោយមានការស្រែក ហៅអោយ ជួយ ពីព្រោះ ព្រះអង្គត្រូវបានពួកវៀតណាមវាយធ្វើបាបរាល់តែថ្ងៃ។ ព្រះតេជគុណ គឹម មឿន ត្រូវបានរងការធ្វើទុក្ខបុកម្នេញដោយក្រុមអ្នកស៊ើបសួរដែលមិនអាច បំភ្លេចបានចំពោះទង្វើដ៏ព្រៃផ្សៃនេះ ពួកគេយកដែកស្រួចបុកទម្លុះរាងកាយ ព្រះអង្គទាំងសងខាងគឺៈ ផ្នែកឆ្អឹងជំនីរ និង នៅគ្រប់ទីកន្លែងលើព្រះភ័ក្ត្ររបស់ព្រះអង្គហើយពួកគេស្រែក។

**-លិខិតសរសេរដោយដៃមួយច្បាប់ជាភាសាខ្មែរសរសេរដោយព្រះសង្ឃមួយព្រះអង្គចំទួសមុខអោយ ព្រះសង្ឃ ទាំង ៥ អង្គដែលជាប់ ពន្ធនាគារ។**

*~~* *~~* *~~*

ពួកគេរំលោភសិទ្ធិជនជាតិភាគតិចរបស់យើង។ យើងគ្មានសិទ្ធិតវ៉ាអំពីការរឹបអូស យកដីធ្លីរបស់យើងទេ។ ប្រសិនបើយើងទាមទារដីរបស់យើងត្រឡប់មកវិញ ពួកគេ និយាយថា យើងចង់ផ្តួលរំលំរដ្ឋាភិបាល និងចាប់ផ្តើមចលនានយោបាយមួយ។

**- អ្នករៀបចំការតវ៉ាខ្មែរក្រោមមួយរូប**

*~~* *~~* *~~*

*ពេលដែលអាត្មាបាននិមន្តទៅដល់វត្តក្រោយពីបានចូលរួមធ្វើបាតុកម្មអាត្មាបានឋិតនៅក្រោមការឃ្លាំមើលលើ ២៤ ម៉ោង ។ ប៉ូលីសបានហ៊ុំព័ទ្ធជុំវិញវត្តយ៉ាងកកកុញជាមួយនឹងអាជ្ញាធរមូលដ្ឋាន ។ ប៉ូលីសបានដើរតាមដានអាត្មាក្នុងពេល អាត្មានិមន្តចេញទៅបិណ្ឌបាត ។ល។ ជាខាងក្រោយមក ប៉ូលីសបាននិយាយជាមួយអាត្មាថា បើសិនជាអាត្មាមិនចង់សឹក ចេញទេ អាត្មាត្រូវតែធ្វើការជាមួយពួកគេ ។ ពួកគេបានបន្ទាប់អាត្មាថា «កិច្ចការងាររបស់អ្នកគឺត្រូវតែតាមដានរាល់សកម្មភាពរបស់ព្រះសង្ឃដទៃទៀត ហើយធ្វើរបាយការណ៍មកយើងខ្ញុំ» ។*

**-ពះតេជគុណ "កុសល" ជាព្រះចៅអធិការមួយព្រះអង្គមកពីខេត្តឃ្លាំង**

The report is available at:
http://www.hrw.org/en/reports/2009/01/21/margins-0